**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៦៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំខែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- អនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង ពីផ្ទៃដីទំហំ១ ៥០០(មួយពាន់ប្រាំរយ)ហិកតា មកផ្ទៃដីទំហំ១ ៤៩២(មួយពាន់បួនរយកៅសិបពីរ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យនិងខេត្តឧត្តរមានជ័យ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់
- ការពារសោភណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិ នៃតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង សម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌មូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់តួនាទីសហគមន៍មូលដ្ឋាន និងវិស័យឯកជន ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តឧត្តរមានជ័យ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមអនុក្រឹត្យស្តីពីតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំវែង ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និង អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣**

**ផែនទីតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ_ភ្នំខែង ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ**






**សញ្ញាសម្គាល់**

- ចំណុចនីយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:30,000

0 0.5 1 2 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

**តំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ_ភ្នំខែង**

មានផ្ទៃដីសរុប ១ ៩៨០ហិកតា

**ប្រភពទិន្នន័យ**

ទិន្នន័យព្រំប្រទល់តំបន់ការពារធម្មជាតិ : ក្រសួងបរិស្ថាន
ព្រំប្រទល់ខេត្ត : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(២០២១)
រូបភាព : Google Earth
ផលិតដោយ : នាយកដ្ឋានសេវាភូមិសាស្ត្រនៃក្រសួងបរិស្ថាន

## ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣
## ចំណុចនិយាមកានៃផែនទីតំបន់បេតិកភណ្ឌធម្មជាតិភ្នំព្រះ-ភ្នំខែច

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 303988 | 1544913 | 16 | 305047 | 1543120 | 31 | 300666 | 1540533 |
| 2 | 304160 | 1544815 | 17 | 304764 | 1543063 | 32 | 300723 | 1540976 |
| 3 | 304400 | 1545093 | 18 | 304750 | 1542872 | 33 | 300923 | 1541519 |
| 4 | 304538 | 1545262 | 19 | 304712 | 1542254 | 34 | 301000 | 1541908 |
| 5 | 304661 | 1545425 | 20 | 304494 | 1542232 | 35 | 301070 | 1542719 |
| 6 | 304721 | 1545318 | 21 | 304328 | 1542108 | 36 | 301053 | 1543023 |
| 7 | 304862 | 1545351 | 22 | 304090 | 1541684 | 37 | 300978 | 1543482 |
| 8 | 304984 | 1545183 | 23 | 303932 | 1541399 | 38 | 301131 | 1543941 |
| 9 | 304914 | 1544973 | 24 | 303482 | 1540981 | 39 | 301207 | 1544343 |
| 10 | 304926 | 1544713 | 25 | 303173 | 1540940 | 40 | 301492 | 1544763 |
| 11 | 304857 | 1544390 | 26 | 302856 | 1540931 | 41 | 301789 | 1544900 |
| 12 | 304742 | 1544228 | 27 | 302199 | 1540839 | 42 | 301955 | 1545059 |
| 13 | 304751 | 1543918 | 28 | 301813 | 1540789 | 43 | 302149 | 1545202 |
| 14 | 305082 | 1543414 | 29 | 301381 | 1540650 | 44 | 302878 | 1545071 |
| 15 | 305229 | 1543163 | 30 | 301190 | 1540525 | 45 | 303562 | 1544937 |